ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាផ្នែករដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណី

លេខ : ២៦៥

ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ២០០០

សាលដីកា

លេខ : ១១៧

ចុះថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០០២

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០០២ ដោយមានសមាសភាព ដូចតទៅ :

១-ឯកឧត្តម ឌិត មុន្ទី ប្រធានក្រុមប្រឹក្សាជំនុំជំរះ
២-លោក វៀល មួន ចៅក្រម
៣-លោក ស៊ុន ឌឹម ចៅក្រម
៤-លោក ជីវ កេង ចៅក្រម
៥-លោក ប្រាក់ គឹមសាន ចៅក្រមរបាយការណ៍
៦-លោក សោម សិរីវឌ្ឍ ចៅក្រម
៧-លោក ឈឹម ស៊ីផល ចៅក្រម
៨-លោក យស់ ហួខឿន ចៅក្រម
៩-លោក គង់ ភីរុន ចៅក្រម

ក្រឡាបញ្ជី លោកស្រី ទី រ៉ាវី

តំណាងមហាអយ្យការ លោក យូន ចាន់ថា ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាលេខ ៨៨៨ ចុះថ្ងៃទី ២០.១២.៩៩ និង សាលក្រមរឿងរដ្ឋប្បវេណីលេខ ៥៧ ចុះថ្ងៃទី ២១.១០.៩៨ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ សាន់ សារុំ ភេទស្រី អាយុ ៥៣ឆ្នាំ ជាតិខ្មែរ របរកស៊ី មន្ត្រីចូលនិវត្ត ទីលំនៅសព្វថ្ងៃ ផ្ទះលេខ ៣១ អឺ០ ផ្លូវលេខ ៥៥០ ក្រុមទី២៤ សង្កាត់បឹងកក់ ១ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ។ និពុកឈ្មោះសាន់ ហុក "ស" ម្តាយឈ្មោះ ស៊ុន សៅ "ស" ។ ដែលមានលោក លឹម វិណ្ណា ជាមេធាវី ។

និង ចុងបណ្តឹងសាទុក្ខឈ្មោះ ហួត គន្ធប ភេទស្រី អាយុ ៤៦ឆ្នាំ ជាតិខ្មែរ របរកស៊ី នៅផ្ទះ ទីលំនៅសព្វថ្ងៃ ផ្ទះលេខ ៣១អឺ១ ផ្លូវ ៥៥០ ក្រុមទី ២៤ សង្កាត់បឹងកក់១ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ។ និពុកឈ្មោះ ហួត ឡាយ "ស" ម្តាយឈ្មោះ យ៉ាវ "រ"។

កម្មវត្ថុបណ្តឹង : សុំបើកច្រកចេញចូល ចំហៀងខាងលិច

តាមបណ្តឹងសាទុក្ខលើកទី២ លេខ ៥៥៧ ចុះថ្ងៃទី ២០.១២.៩៩ របស់ឈ្មោះ

សាន់ សារុំ ប្តឹងមិនសុខចិត្តពីសាលដីកាលេខ ៨៨៨ ចុះថ្ងៃទី ២០.១២.៩៥ របស់សាលាឧទ្ធរណ៍ លើចំនុច នៃ សេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២៦៥ ចុះថ្ងៃទី ១១.៧.២០០០ របស់ តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ២១.៥.៩៤ របស់ដើមចោទឈ្មោះ ហួតគន្ធ ប្តឹងទាមទារអាងទឹកទំហំ ២,៥០ម គុណ ១,៥០ម និង ដី ដែលមានទំហំ ៤ម គុណ២៥ម ជាផ្លូវសំរាប់ដើរទៅអាងទឹក ដោយហេតុថា អាងទឹកជារបស់ខ្លួន ដែលធ្លាប់ប្រើប្រាស់តាំងពីឆ្នាំ ៨៣ មកម្លេះ ។ ឯដីគឺខ្លួនបានទិញពីចុងចម្លើយ នៅឆ្នាំ ១៩៩១ ដែលមានតម្លៃ ២០០ ដុល្លារអាមេរិក ។

បានឃើញសាលក្រមលេខ ៩៤ "គ" ចុះថ្ងៃទី ២៨.៨.៩៦ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១ -ទទួលពាក្យបណ្តឹងចុះថ្ងៃទី ២១.៥.៩៤ របស់ដើមចោទឈ្មោះនារី ហួត គន្ធ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២ -ប្រគល់អាងទឹកដែលមានបណ្តោយ ២,៥០ម និង ទទឹង ១,៥០មស្ថិតនៅចំហៀងខាងលិចផ្ទះលេខ ៣១អឺ០ អឺ១ ផ្លូវ ៥៥០ ក្រុម ២៤ សង្កាត់បឹងកក់ទី១ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ទៅអោយនារី ហួត គន្ធ កាន់កាប់ប្រើប្រាស់ និង ថែរក្សា ចាប់តាំងពីសាលក្រមចូលជាស្ថាពរតទៅ ។

៣ -ប្រគល់ដីផ្លូវដើរដែលមានបណ្តោយ ២៥ម និង ទទឹង ៤ម ស្ថិតនៅចំហៀងខាងលិចផ្ទះលេខ ៣១អឺ០ អឺ១ ផ្លូវ ៥៥០ ក្រុម២៤ សង្កាត់បឹងកក់១ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ទៅអោយនារី ហួត គន្ធ កាន់កាប់ថែរក្សា ចាប់តាំងពីសាលក្រមចូលជាស្ថាពរតទៅ ។

៤-បង្គាប់អោយនារី ហួត គន្ធ បង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី ពន្ធថ្លឹង ១.៨០០៛ រង្វាន់ក្រឡាបញ្ជីកានហិបប្រាក់ ២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ៥០០០៛ បូកសរុប ៧.០០០៛ ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០៛ ដែលដើមចោទបានបង់ទុកជាស្រេច ។

កាលបើហួសឧទ្ធរណ៍ បង្គាប់អោយនារី សាន់ សារុំ សងប្រាក់ ៧.០០០៛ ទៅដើមចោទវិញ និង អោយបង់ពន្ធសមាមាត្រមួយភាគរយលើតម្លៃដីទំនាស់ទាំងមូល ប្រាក់នេះត្រូវបង់ចូលថវិការដ្ឋ ៨០ភាគរយ និង បានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០ភាគរយ តាមច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី ។

៥ -សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខគូក្តី សំរេចបើកផ្លូវ

ឧទ្ធរណ៍ក្នុងរយៈពេល២ខែ គិតចាប់តាំងពីថ្ងៃនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ សាន់ សារុំ ចុះថ្ងៃទី ០២.៩.៨៦ ប្តឹងមិនសុខចិត្តលើសេចក្តីសំរេច នៃ សាលាក្រមទាំងមូល ។

បានឃើញសាលដីកា របស់សាលាឧទ្ធរណ៍លេខ ៤៣១ ចុះថ្ងៃទី ១២.៨.៨៧ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ របស់ឈ្មោះ សាន់ សារុំ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែអំពីគតិច្បាប់លើកចោលខ្លះ ទុកខ្លះ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៨៤ "គ" ចុះថ្ងៃទី ២៨.៨.៨៦ របស់ តុលាការក្រុងភ្នំពេញ ទុកជាបានការ តែត្រូវកែប្រែដូចតទៅ អាងទឹកដែលមានបណ្តោយ ២,៥០ម ទទឹង ១,៥០ម ស្ថិតនៅចំហៀងខាងលិចផ្ទះលេខ ៣១អឺ០ អឺ១ ផ្លូវលេខ ៥៥០ ក្រុមទី២៤ សង្កាត់បឹងកក់ទី១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ត្រូវខ័ណ្ឌជាពីរ ប្រគល់អោយដើមចោទប្រើប្រាស់ពាក់កណ្តាល ចុងចម្លើយប្រើប្រាស់ពាក់កណ្តាល ផ្លូវដើរដែលមានបណ្តោយ ២៥ម គុណ ៤ម ស្ថិតនៅចំហៀងខាងលិចផ្ទះលេខ ៣១អឺ០ អឺ១ ផ្លូវលេខ ៥៥០ ក្រុម ២៤ សង្កាត់បឹងកក់១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ត្រូវអោយចុងចម្លើយបើកអោយដើមចោទប្រើប្រាស់ផងដែរ ។

៣-រឹបអូសប្រាក់ប្រដាប់ក្តី ដាក់សាលាឧទ្ធរណ៍ ១៣.០០០៛ គឺពន្ធពិន័យនិងពន្ធចុះបញ្ជីក្តី ២.៥៥០៛ រង្វាន់ក្រឡាបញ្ជីការទីបប្រាក់ ៤៥០៛ ចំណាយលើកិច្ចប្រគល់ដី ការកោះ និង អាជ្ញាធរ តុលាការ ១០.០០០៛ សរុប ១៣.០០០៛ ។ ប្រាក់នេះដើមបណ្តឹងឧទ្ធរណ៍ បានបង់ហើយ ។

៤-សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខ ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខ របស់ឈ្មោះ ហួត គន្ធប ចុះថ្ងៃទី ១៥.៨.៨៧ និង បណ្តឹងសាទុក្ខរបស់ ឈ្មោះ សាន់ សារុំ ចុះថ្ងៃទី ១១.៩.៨៧ ប្តឹងមិនសុខចិត្ត លើសេចក្តីសំរេច នៃ សាលដីកាទាំងមូល ។

បានឃើញសាលដីការបស់ តុលាការកំពូលលេខ ១៩៥ ចុះថ្ងៃទី ២៨.៨.៨៨ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១-ទទួលបណ្តឹងសាទុក្ខលេខ ៣០៧ ចុះថ្ងៃទី ១៥.៨.៨៧ របស់អ្នកស្រី ហួត គន្ធប និង បណ្តឹងសាទុក្ខលេខ ៣៣៩ ចុះថ្ងៃទី ១១.៩.៨៧ របស់អ្នកស្រី សាន់ សារុំ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ទុកជាមោឃៈ សាលដីការដ្ឋប្បវេណីលេខ ៤៣១ ចុះថ្ងៃទី ១២.៨.៨៧

របស់ សាលាឧទ្ធរណ៍ទាំងមូល ។

៣ -បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ៣០៨ ចុះថ្ងៃទី ២១.១០.៩៧ របស់ តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤ -ទីបរិវត្តប្រាក់ប្រដាប់ក្តីចំនួន ៣៨.០០០៛ ដែលគូភាគីបានបង់រួចហើយ គឺ :

-ពន្ធចុះបញ្ជីក្តី និង ពន្ធថ្លឹង ចំនួន ៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សម្រាប់ផ្សារង្វាន់ក្រឡាបញ្ជីកាន់បញ្ជីប្រាក់ .

-ចំណាយលើកិច្ចប្រគល់ដីការកោះ ចំនួន ១៥.០០០៛ សរុប ១៩.០០០៛ នៅសល់ ១៩.០០០៛ បង្វិលអោយគូភាគី ពាក់កណ្តាលម្នាក់វិញ ។

៥ -សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ២៨ ខែសីហា ឆ្នាំ ១៩៩៨ ។

បានឃើញសាលដីការបស់សាលាឧទ្ធរណ៍ លេខ ៨៨៩ ចុះថ្ងៃទី ២០.១២.៩៩ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១ -ទទួលជំនុំជំរះ ជាសមត្ថកិច្ច ដោយសាលដីការដ្ឋប្បវេណីលេខ ១៨៥ ចុះថ្ងៃទី ២៨.៨.៩៨ របស់តុលាការកំពូល សំរេចបង្វិលសំណុំរឿងនេះ មកអោយសាលាឧទ្ធរណ៍ជំនុំជំរះឡើងវិញ តាមមាត្រា១១ នៃច្បាប់ ស្តីពីការចាត់តាំង និង សកម្មភាព របស់សាលាជំរះក្តី ។

២ -តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៩៤ "ក" ចុះថ្ងៃទី ២៨.៨.៩៦ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល ។

សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខគូក្តី និង មេធាវី របស់ ចុងចម្លើយ សំរេចបើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលើកទី ២ របស់ឈ្មោះ សាន់ សារុំ ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ១៩៩៩ ប្តឹងមិនសុខចិត្ត លើសេចក្តីសំរេច នៃ សាលដីកាទាំងមូល ។

បានឃើញសាលដីការបៀប របស់តុលាការកំពូល លេខ២០១ ចុះថ្ងៃទី ០៦.១២.២០០១ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១ -ចាត់របៀប អោយចៅក្រម តុលាការកំពូល ចុះពិនិត្យផលទីតាំងដីទំនាស់ ។

២ -សាលដីកានេះ ប្រកាស នាសវនាការ ជាសាធារណៈ នៅថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ ២០០១ ។

បានស្តាប់របាយការណ៍ បន្ថែម របស់ចៅក្រមរបាយការណ៍

បានស្ដាប់សេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការ អម តុលាការកំពូល ថា

-បណ្ដឹងសាទុក្ខរបស់ ចុងចម្លើយ ធ្វើឡើងស្ថិតនៅក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យពិចារណា ។

-សាលដីការបស់សាលាឧទ្ធរណ៍ ដែលសំរេចសេចក្ដីមកនេះ មានលក្ខណៈ ផ្ទុយនឹង គតិច្បាប់ ហេតុនេះសូមក្រុមប្រឹក្សាជំនុំជំរះ សំរេចតាមច្បាប់ ។

បានស្ដាប់ចម្លើយរបស់ឈ្មោះ លាន់ សារុំ ជាម្ចាស់បណ្ដឹងសាទុក្ខ នៅពេលជំនុំជំរះឆ្លើយថា :

-ខ្លួនសុំយកដីនេះមកគ្រប់គ្រងវិញ ព្រោះខ្លួនមិនបានលក់ទៅអោយ ឈ្មោះ ហួត គន្ធប ទេ ហើយក៏ពុំបានទទួលលុយដែរ ។ បង្ក្រានបាយ បន្ទប់ទឹក បង្គន់ ជារបស់ខ្លួនគ្រប់គ្រង ។ កាលពីដើមគាត់ដើរក្រោយបង្គន់ ដល់ពេលឥឡូវ សុំដើរពីមុខបង្គន់ ។ ចំពោះអាងទឹកជារបស់រួមមានតាំងពីសង្គម កាលពីឆ្នាំ ៨៥ ទឹកក្នុងអាងនេះចេញ ដល់ឆ្នាំ ៩០ ឈប់ចេញ គេឈប់ប្រើទាំងអស់គ្នា ទុកចោល ។

បានស្ដាប់ចម្លើយរបស់ឈ្មោះ ហួត គន្ធប ជាចុងបណ្ដឹងសាទុក្ខ នៅពេលជំនុំជំរះឆ្លើយថា :

-ផ្ទះនេះជាផ្ទះរបបរដ្ឋអោយប្ដីខ្លួន ខ្លួនបានសុំទិញដីគាត់ចំហៀងខាងលិចផ្ទះក្នុងតំលៃ ២០០ដុល្លាអាមេរិក តែគាត់ថាមិនបានទទួលលុយ ហើយក៏បិទផ្លូវនោះទៅ កាលទទួលលុយ គាត់ និង កូនគាត់ ជាអ្នកទទួល ដោយសរសេរជាលាយលក្ខអក្សរ ។ រោងបាយពីមុនគ្មានទេ គាត់ទើបតែសង់ ចំពោះអាងទឹកជារបស់ប្ដីខ្លួនសង់នៅឆ្នាំ៨៦ ទោះបីសាក្សីដែលធ្លាប់ប្រើប្រាស់ទឹក ក្នុងអាងនេះ ក៏ឆ្លើយថា ជារបស់ខ្លួនដែរ ។ សុំអោយចុងចម្លើយបើកផ្លូវ អោយខ្លួនបានដើរចេញ ចូលផង ។

មេធាវី របស់ ចុងចម្លើយធ្វើសេចក្ដីសន្និដ្ឋាន ថា

-លិខិតដែលឈ្មោះ ហួត គន្ធប យកមកធ្វើសំអាងនេះ មិនអាចយកជាការបានទេ ព្រោះគ្មានការចុះការបរិច្ឆេទ ។ នៅឆ្នាំ ៩២ ឈ្មោះ ហួតគន្ធប និង កូនក្ដីខ្លួន បានរួមគ្នា លក់ដីអោយឈ្មោះ ថោង ចាន់ដារា ក្នុងតំលៃ ៦០០ដុល្លាអាមេរិក ដីរបស់កូនក្ដីខ្លួនលក់បាន ២០០ដុល្លា ហួត គន្ធប លក់បាន ៤០០ដុល្លា នៅពេលថោង ដារ៉ា ប្រគល់លុយ កូនក្ដីខ្លួន មិននៅ ក៏ប្រគល់លុយនេះអោយ ហួត គន្ធប ទុកអោយកូនក្ដីខ្លួន តែ នៅពេល ហួតគន្ធប យកលុយមកអោយកូនក្ដីខ្លួន គាត់អោយកូនក្ដីខ្លួន សរសេរលិខិត ថាពិតជាបានទទួលលុយ ២០០ដុល្លាពិតមែន តែប៉ុណ្ណោះ មិនមែនជាកិច្ចសន្យាទិញ លក់ដីទេ

ហើយគាត់សុំអោយកូនក្តីខ្លួនបើកផ្លូវខាងជើង មុខបង្គន់ ដើម្បីគាត់ឆ្លងកាត់ ទៅដីរបស់គាត់ ។ ចំពោះដីប៉ែកខាងលិចផ្ទះ ជាប់ល្វែងផ្ទះលេខ ៣១អឺ០ កូនក្តីខ្លួនជាអ្នកថែរក្សា គ្រប់គ្រងកាន់កាប់ មកដល់បច្ចុប្បន្ន ចំពោះដំណាំនៅលើដីនោះ ក៏ជារបស់កូនក្តីខ្លួនជាអ្នកអាស្រ័យផល ចំពោះអាងទឹកក្រោយពីឈប់ប្រើរួម កូនក្តីខ្លួនជាអ្នកគ្រប់គ្រង ព្រោះស្ថិតនៅលើដី របស់កូនក្តីខ្លួន ។ សុំបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ទាំងមូល ។

-ក្រោយពីបានស្តាប់ របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចំឡើយ ដោះសារ របស់គូភាគី និង សេចក្តីសន្និដ្ឋាន របស់មេធាវី របស់អ្នកស្រី សាន់ សារុំ

-ក្រោយពីបាន ពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលើកទី២ លេខ ៥៥៧ ចុះថ្ងៃទី ២០.១២.៩៩ របស់អ្នកស្រី សាន់ សារុំ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបាន តាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាព របស់សាលាជំរះក្តី និង តាមមាត្រា ២២៦ នៃច្បាប់ ស្តីពី នីតិវិធីព្រហ្មទណ្ឌ ដែលអាចអនុវត្តបាន ក្នុងរឿង រដ្ឋប្បវេណី ផងដែរ ។

-យល់ឃើញថា ការដែលអ្នកស្រី សាន់ សារុំ លើកឡើងក្នុងសារណា ចុះថ្ងៃទី ០៤.៩.២០០០ ថា អាងទឹកទំហំ ២,៥ម៉ែត្រ គុណ ១,៥ម៉ែត្រ ជាអាងទឹកប្រើប្រាស់រួម នោះ តុលាការកំពូល ពុំអាចយកជាការបានឡើយ ពីព្រោះអ្នកស្រីបានឆ្លើយ ទទួលស្គាល់ នៅតុលាការថ្នាក់ក្រោម និង នៅ តុលាការកំពូល លើកទី១ ថា អាងទឹកនេះ ពិត ជារបស់ដើមចោទ មែន ។

-យល់ឃើញថា ការដែលអ្នកស្រី ហួត គន្ធច ទាមទារដីទំនាស់នេះ ទាំងមូលដោយ អាងលើលិខិតទទួលប្រាក់ ដែលគ្មានចុះ ថ្ងៃខែឆ្នាំ នោះ តុលាការពុំអាច ពិចារណាបានឡើយ ពីព្រោះលិខិតនេះ ពុំមានសុពលភាព អាចយកជាការបានទេ ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ សំរេចប្រគល់ដីផ្លូវដើរដែល មានបណ្តោយ ២៥ម៉ែត្រ ទទឹង ៤ម៉ែត្រ ស្ថិតនៅចំហៀងផ្ទះខាងលិច ផ្ទះលេខ ៣១អឺ០ និង អឺ១ ទៅអោយអ្នកស្រី ហួត គន្ធច កាន់កាប់ថែរក្សា ទាំងស្រុង នោះជាការពុំត្រឹមត្រូវទេ ពីព្រោះដីចំណីផ្ទះ គឺជាដីបំរើអោយសេវភាពរួម ហើយមានភស្តុតាងគ្រប់គ្រាន់ បញ្ជាក់ថា មុនពេលមានទំនាស់ គូភាគីពិតជាបាន ប្រើប្រាស់ ដីទំនាស់នេះរួមគ្នា មែន ។

-យល់ឃើញថា អ្នកស្រី ហួត គន្ធច មានដីរបស់ខ្លួននៅខាងក្រោយ ដែលចាំបាច់ត្រូវតែប្រើប្រាស់ដី សេវភាពនេះ ដើម្បីចេញចូល ទៅដីរបស់អ្នកស្រី ។ ប៉ុន្តែបើទុកដីទំនាស់នេះ អោយនៅតែប្រើប្រាស់រួមគ្នា តទៅទៀត ធ្វើអោយគូភាគី មិនអាចជៀសផុត ពីទំនាស់បានឡើយ ។ ដូច្នេះគប្បីធ្វើការបែងចែក ដីទំនាស់អោយគូភាគី ប្រើប្រាស់ដាច់ដោយឡែកពីគ្នា ដើម្បីបញ្ចប់ទំនាស់ ។

-យល់ឃើញថា នៅលើដីទំនាស់ មានអាងទឹករបស់អ្នកស្រី ហួត គន្ធច មានបង្គន់ និង ដំណាំរបស់អ្នកស្រី សាន់ សារុំ ដូច្នេះគប្បីធ្វើការផ្លាស់ប្តូរគ្នា អោយបានសមស្រប គឺ ប្រគល់អាងទឹកអោយទៅអ្នកស្រី សាន់ សារុំ ហើយបង្គាប់អោយអ្នកស្រីសាន់សារុំ រុះរើបង្គន់ចេញ ដើម្បីទុកផ្លូវអោយអ្នកស្រី ហួត គន្ធច ដើរឆ្លងកាត់ ទៅដីរបស់អ្នកស្រីខាងក្រោយ ហើយបង្គាប់អោយអ្នកស្រី ហួត គន្ធច ចេញថ្លៃដំណាំ នៅលើចំណែកដី ដែលត្រូវបានទៅអ្នកស្រី ហួត គន្ធច អោយទៅអ្នកស្រី សាន់ សារុំ ។

-យល់ឃើញថា ដើម្បីបង្កលក្ខណៈងាយស្រួល ក្នុងការប្រើប្រាស់ និង ជៀសវាងទំនាស់ជាថ្មីទៀត គប្បីបែងចែកដីទំនាស់នេះ ដោយគិតពីរបងមុខ មកទល់ជើងជណ្តើរ ទៅផ្នែកខាងលិច ហើយកាច់ទៅជើង ស្របតាមរបង ដោយគិតពីរបងខាងលិចមកកើត ប្រវែងពីរម៉ែត្រ "០២ម៉ែត្រ" ត្រង់ទៅទល់របងខាងជើង ដោយទុកប្រវែង០២ម៉ែត្រ "ពីរម៉ែត្រ" ពីរបង រួចកាច់ទៅកើតវិញ រហូតដល់ដី អ្នកស្រី ហួត គន្ធច ប្រគល់អោយអ្នកស្រី ហួតគន្ធច តាមគំនូសពណ៌ក្រហម នៅលើគំនូសប្លង់ ចុះថ្ងៃទី ០៤.០១.២០០២ របស់ចៅក្រមតុលាការកំពូល ហើយដីទំនាស់ នៅសល់ពីនេះ ប្រគល់អោយអ្នកស្រី សាន់ សារុំ ។

-យល់ឃើញថា ដោយជើងជណ្តើរ របស់អ្នកស្រី ហួត គន្ធច បែរមុខមករកដីមុខផ្ទះល្វែង របស់ អ្នកស្រី សាន់ សារុំ គប្បីសំរេចអោយអ្នកស្រី ហួត គន្ធច បំបែរជើងជណ្តើរ របស់អ្នកស្រី មកដាក់លើដីដែលតុលាការប្រគល់អោយអ្នកស្រី វិញ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៨៨៨ ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានការខុសឆ្គង ទាំងទំរង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី ចំពោះមុខ គូក្តី

១ -ទទួលបណ្តឹងសាទុក្ខលើកទី២ លេខ ៥៥៧ ចុះថ្ងៃទី ២០.១២.៩៩ របស់អ្នកស្រី សាន់ សារុំ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២ -ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ៨៨៨ ចុះថ្ងៃទី ២០.១២.៩៩ របស់សាលាឧទ្ធរណ៍ ទាំងមូល ។

៣-សំរេចប្រគល់ដី តាមគំនូស ពណ៌ក្រហម លើប្លង់បង្ហាញទីតាំងទំនាស់ ចុះថ្ងៃទី ០៤.០១.២០០២ របស់ចៅក្រមតុលាការកំពូល អោយទៅអ្នកស្រី ហួត គន្ធច ដីនៅសល់ពីនេះ ប្រគល់អោយអ្នកស្រី សាន់ សារុំ ។

៤-សំរេចប្រគល់អាងទឹក អោយអ្នកស្រី សាន់ សារុំ ប៉ុន្តែបង្គាប់អោយ អ្នកស្រី សាន់ សារុំ រុះរើបង្គន់ របស់អ្នកស្រី ដែលស្ថិតនៅលើចំណែកដី ដែលត្រូវបានទៅ អ្នកស្រី ហួត គន្ធច ទៅសង់លើដីខ្លួនវិញ ដើម្បីទុកអោយអ្នកស្រី ហួត គន្ធច ចេញចូល ទៅដីរបស់អ្នកស្រី បាន ។

៥-បង្គាប់អោយអ្នកស្រី ហួត គន្ធច ចេញថ្លៃដំណាំរបស់អ្នកស្រី សាន់ សារុំ ដែលស្ថិតនៅលើចំណែកដី ដែលត្រូវបានទៅអ្នកស្រី ហួត គន្ធច ចំនួន ១លាន ៥សែនរៀល អោយទៅអ្នកស្រី សាន់ សារុំ ។

៦-បង្គាប់អោយអ្នកស្រី ហួត គន្ធច បង្វែរទិសជើងដំបូល របស់អ្នកស្រី មកចុះលើ ចំណែកដី ដែលត្រូវបានទៅអ្នកស្រី វិញ ។

៧-រឹបអូសប្រាក់ប្រដាប់ក្ដី ចំនួន ១៩.០០០៛ ដែលអ្នកស្រី សាន់សារុំ បានបង់ រួចហើយ គឺ :

-ពន្ធចុះបញ្ជីក្ដី និង ពន្ធហ៊ឹង ចំនួន ៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវ កាត់ ចំនួន ៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកានហិបប្រាក់ .

-ចំណាយលើកិច្ចប្រគល់ដីការកោះ ចំនួន ១៥.០០០៛ សរុប

១៥.០០០៛ ហើយតម្រូវអោយអ្នកស្រី ហ៊ួត គន្ធច សងប្រាក់ ១៥.០០០៛ នេះទៅអ្នកស្រី សាន់ សារុំ វិញ ។

៨-សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០០២ ។